

លេខ ១៧

# គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា

ខែ កុម្ភៈ ឆ្នាំ ២០១៤

ព្រឹត្តិបត្រព័ត៌មានប្រចាំត្រីមាស

## ព្រឹត្តិការណ៍សំខាន់ៗ

ដោយបេសកកម្មរយៈពេល៥ឆ្នាំត្រូវបានចាប់ផ្តើម IBEC បានធ្វើការទៅលើ ៖

- សាលាបឋមសិក្សាចំនួន ១៤៥
- សាលាមធ្យមសិក្សាចំនួន ១៤៧
- បង្កើតសៀវភៅសិក្សាបំណិនជីវិតចំនួន ៣០ប្រធានបទ
- ពង្រីកសកម្មភាពទៅកាន់ខេត្តថ្មីចំនួន ៣ ៖ ស្វាយរៀង ព្រៃវែង និងកំពង់ធំ
- ធ្វើការជាមួយសាលារៀនសរុបចំនួន ៣២២

អត្រាសិស្សចុះឈ្មោះចូលរៀន ៖

- ១២២,៩៥០នាក់ (ស្រី ៦១,០១៨នាក់) តាមសាលារៀនគោលដៅ
- ១៣៦,៣៨៣នាក់ (ស្រី ៦៧,៥១៩នាក់) ក្នុងខេត្តទាំង ៦



សិស្សក្នុងគម្រោង IBEC សម្តែងរឿងខ្លីក្នុងពិព័រណ៍សាលារៀន

ការបោះពុម្ពព្រឹត្តិបត្រព័ត៌មានរបស់គម្រោង IBEC នេះគឺដើម្បីរាយការណ៍អំពីព្រឹត្តិការដែលបានអនុវត្តក្នុងត្រីមាសទី១៧ (ពីខែតុលា ដល់ខែធ្នូ ឆ្នាំ២០១៣) គឺជាត្រីមាសដែលគម្រោង IBEC កំពុងចាប់ផ្តើមការងារឆ្នាំទី៥របស់ខ្លួន និងជាឆ្នាំចុងក្រោយនៃការអនុវត្តគម្រោង ។ នេះជាឆ្នាំដ៏សំខាន់ក្នុងការអនុវត្តគម្រោងដែលផ្តោតទៅលើការប្រគល់ការងារសកម្មភាពរបស់គម្រោងទាំងអស់ឱ្យទៅរដ្ឋាភិបាល និងអង្គការដៃគូអភិវឌ្ឍន៍ផ្សេងៗ ។



បច្ចេកវិទ្យាព័ត៌មាន



ភាពស្មើភាពក្នុងការចូលសាលារៀន



កម្មវិធីបំណិនជីវិត

USAID FROM THE AMERICAN PEOPLE

អង្គការអប់រំពិភពលោក WORLD EDUCATION

## សមាសភាគ១ ៖ ការកសាងសមត្ថភាពមន្ត្រីរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងស្វែងរកការគាំទ្រដើម្បីនិរន្តរភាព

សកម្មភាពកសាងសម្ថភាពត្រូវបានចាត់ទុកថា ជាសកម្មភាពដ៏សំខាន់ក្នុងពេលដែលឆ្នាំសិក្សាថ្មីបានចាប់ផ្ដើម ខណៈពេលដែលនេះជា ឆ្នាំចុងក្រោយរបស់ IBEC ក្នុងការជួយគាំទ្រសាលារៀនគោលដៅ ។ យោងតាមការសង្កត់ធ្ងន់របស់សមាសភាគនីមួយៗទៅលើការពង្រឹង ទំនាក់ទំនងរវាងសាលារៀន និងក្រុមប្រឹក្សាឃុំ ក្នុងគោលបំណងដើម្បីបញ្ចូលផែនការអភិវឌ្ឍន៍សាលារៀនក្នុងផែនការវិនិយោគឃុំ នៅពេលដែលអាជ្ញាធរឃុំតាំងចិត្តផ្ដល់ថវិកាចំនួន៧,៤៣៧ ដុល្លា សម្រាប់ជាទុនបដិភាគដល់សាលារៀនចំនួន៥០ក្នុងតំបន់គោលដៅ ។ ការខិតខំប្រឹងប្រែងជួយគាំទ្រដល់ផែនការនិរន្តភាព សម្រាប់សាលារៀនទាំងអស់ គឺជាយុទ្ធសាស្រ្តសំខាន់របស់គម្រោងដើម្បីធានាបានទូវនិរន្តភាព នៃការវិនិយោគរបស់គម្រោងក្នុងពេលកន្លងមក សកម្មភាពទាំងនោះរួមមាន ការបន្តពិភាក្សាជាមួយក្រុមពិគ្រោះយោបល់ថ្នាក់ជាតិ ក៏ដូចជាក្រុមការងារថ្នាក់ខេត្តដើម្បីរៀបចំការដាក់ឱ្យដំណើរការ និងព្រឹត្តិការណ៍ផ្ទេរភារកិច្ច និងការជំរុញឱ្យក្រសួងអប់រំទទួលយកសកម្មភាពរបស់គម្រោងជាផ្លូវការរួមមាន សៀវភៅសិក្សាបំណិនជីវិតជាដើម ។

## សមាសភាគ២ ៖ ការបង្កលទ្ធភាពទទួលបានការអប់រំប្រកបដោយសមធម៌

### *កម្មវិធីអាហារូបករណ៍ ៖*

សកម្មភាពអំពីភាពងាយស្រួលចូលសាលារៀន ត្រូវបានគេកម្រិតលើការផ្ដល់អាហារូបករណ៍ក្នុងដំណាក់កាលចុងក្រោយ ចំពោះកុមារងាយរងគ្រោះដែលបានជ្រើសរើសពីដំបូងដោយគម្រោង និងបង្រួមការគូសផែនទីសាលារៀននៅតាមសាលាណាដែលធ្វើបច្ចុប្បន្នភាព ផែនទីសាលារៀនរបស់ខ្លួន ដើម្បីកំណត់កុមារក្រៅសាលាក្នុងពេលកន្លងមក ។

សាលារៀនបានរាយការណ៍ថា ខ្លួនបានកំណត់កុមារក្រៅសាលាបន្ថែមចំនួន៥៧នាក់ទៀតនៅបឋមសិក្សា និងមធ្យមសិក្សា ដែល២៦នាក់ក្នុងចំណោមពួកគេបានចុះឈ្មោះចូលរៀនឡើងវិញស្មើនឹង ៤៦% ។ ខណៈពេលដែលគេជឿថានៅមានកុមារជាច្រើនទៀតឋិតនៅក្រៅសាលារៀន យើងជឿថាកុមារទាំងនេះត្រូវបានបំលាស់ទីដើម្បីស្វែងរកការងារធ្វើ ឬក៏រស់នៅឆ្ងាយពីសាលារៀន ។

អាហារូបករណ៍បឋមសិក្សាបានបន្តក្នុងកម្រិតកាត់បន្ថយជាមួយនឹងការគាំទ្រមកពីថវិកាឃុំ និងមូលនិធិជំនួយសាលារៀន ដើម្បីនិរន្តភាពដែលគាំទ្រដោយធនធានសិក្សា នេះជាសកម្មភាពរកប្រាក់ចំណូលដែលបង្កើតឡើងដោយគម្រោងក្នុងឆ្នាំទី៣ ដើម្បីលក់សំភារៈបង្រៀន ។ កុមារទទួលអាហារូបករណ៍សរុបចំនួន ៤១៨នាក់ក្នុងឆ្នាំនេះ ។ នៅមធ្យមសិក្សាសិស្សទទួលអាហារូបករណ៍សរុបចំនួន ៧១២នាក់ ដែលពួកគេទាំងអស់រៀននៅថ្នាក់ទី ៩ ។

### *កញ្ចប់ថវិកាដែលដឹកនាំដោយអ្នកពាក់ព័ន្ធ ៖*

នៅចុងត្រីមាសនេះ ការិយាល័យតាមខេត្តបានរាយការណ៍ថាគម្រោងនៅតែបន្តគាំទ្រដល់សាលារៀនដែលខ្វះគ្រូ និងគ្រូសហគមន៍ចំនួន៣៩នាក់ ។ ចំនួននេះត្រូវថយចុះពីចំនួនដំបូងដែលយើងបានជួយក្នុងការដោះស្រាយបញ្ហាខ្វះគ្រូ។ ទោះជាយ៉ាងណាក៏ដោយ ថវិកាសម្រាប់ក្រុមប្រឹក្សាកុមារក៏ត្រូវបានផ្ទេរទៅឱ្យក្រុមប្រឹក្សាឃុំ (សម្រាប់សាលារៀនដែលជ្រើសរើសយកជំនួយពីថវិកាឃុំ) គម្រោងក៏បានបន្តផ្ដល់ការគាំទ្រដល់ការកសាងសមត្ថភាពផងដែរ ។ ក្នុងន័យនេះមន្ត្រីសម្របសម្រួលតាមស្រុកបានបើកវគ្គសិក្ខាសាលារំលឹកឡើងវិញដល់សាលារៀនចំនួន ១៣២ ។

មានសកម្មភាពអភិវឌ្ឍសាលារៀនជាច្រើនដែលសាលាបានកំណត់ក្នុងផែនការនិរន្តភាពរបស់ខ្លួនដោយប្រើថវិកាពីឃុំ និងប្រភពជំនួយផ្សេងៗ ។

**សមធម៌នៃការចូលសាលារៀន ៖ សិស្សស្រីក្នុងពេលសម្រាកពីការសិក្សា**



សកម្មភាពទាំងនោះរួមមាន ៖

- ការជួយគាំទ្របណ្ណាល័យ (៥១សាលារៀន)
- បណ្ដាញកុមារជួយកុមារ (១៤សាលារៀន)
- ប្រអប់សង្គ្រោះបឋម (៤៥សាលារៀន)
- ក្រុមប្រឹក្សាកុមារី (៣២សាលារៀន)
- បុណ្យសាលារៀនដើម្បីបង្កើនការចុះឈ្មោះចូលរៀនដើមឆ្នាំសិក្សា (២៣សាលារៀន)

ក្រុមការងារផ្នែកកសាងហេដ្ឋារចនាសម្ព័ន្ធ បានធ្វើការស្រាវជ្រាវទៅលើសាលារៀនណាដែលត្រូវការជួសជុលឡើងវិញនូវបង្គន់អនាម័យ និងប្រព័ន្ធទឹកស្អាត ហើយតាមរយៈការស្រាវជ្រាវក្រុមការងារបានសម្រេចជួសជុលដូចខាងក្រោម ៖

- កន្លែងលាងដៃចំនួន ៥៥
- អណ្ដូងទឹកចំនួន ១
- បង្គន់ចំនួន ៣០ និង
- ប្រព័ន្ធទឹកស្អាតចំនួន ១៧

ខណៈពេលដែលសាលារៀនជាច្រើនមានភាពឧស្សាហ៍ក្នុងការថែរក្សានូវសមិទ្ធិផលទាំងនេះ ក៏មានសាលារៀនមួយចំនួនទៀតមិនមានការថែរក្សាបានល្អឡើយ ឬពុំយកចិត្តទុកដាក់ក្នុងការថែរក្សា ដែលជាហេតុតម្រូវឱ្យមានការជួសជុល ។ ក្រុមការងាបានព្យាយាមផ្ដល់នូវការបំប៉នបន្ថែមដល់សាលារៀនទាំងនេះ និងជំរុញឱ្យមន្ត្រីមូលដ្ឋានជួយគាំទ្រ និងទប់ស្កាត់បញ្ហានេះទៅថ្ងៃអនាគត ។

## គ្រូដែលមានសិស្សស្រឡាញ់រាប់អានច្រើនជាងគេ

អ្នកគ្រូវ័យក្មេង និងមានការតាំងចិត្តខ្ពស់នៅបឋមសិក្សាម្នាក់គឺអ្នកគ្រូ អៀង គាត់បានចាប់ផ្តើមបង្រៀនក្នុងឆ្នាំ២០០៨ ។ ដោយទទួលបាននូវវគ្គបំប៉នផ្នែកកសាងសមត្ថភាពពីគម្រោង IBEC គាត់បានក្លាយជាគ្រូដែលមានភាពលេចធ្លោ និងទទួលបានការសរសើរយ៉ាងខ្លាំងពីសហគមន៍របស់គាត់។

អ្នកគ្រូ អៀង បង្រៀននៅថ្នាក់ទី១ក្នុងសាលាបឋមសិក្សាជៀស ក្នុងខេត្តកំពង់ចាម ដែលជាសាលារៀនមានការរៀបចំបរិស្ថានបានល្អ និងមានភាពស្រស់ស្អាត។ គាត់បង្រៀនទាំងសិស្សខ្មែរ និងសិស្សចាម ដែលធ្វើឱ្យគាត់ជួបនូវការលំបាកក្នុងការបង្រៀនដោយនិយាយភាសាខ្មែរ ។ អ្នកគ្រូ អៀង តែងតែបង្រៀនសិស្សរបស់គាត់ដោយបានរៀបចំនូវកិច្ចតែងការបង្រៀនចំពោះគ្រប់មុខវិជ្ជា ។ ជាមួយនិងជំនាញក្នុងការបង្កើតសម្ភារឧបទេសដែលគាត់បានរៀនពី IBEC គាត់បានបង្កើតនូវសម្ភារៈបង្រៀនថ្មីៗជាច្រើនសម្រាប់ការបង្រៀនភាសាខ្មែរ និងគណិតវិទ្យា ក៏ដូចជាពង្រឹងការសិក្សាក្នុងថ្នាក់ជាមួយ និងផ្ទស្ទ័រអប់រំមួយចំនួន និងការតាំងបង្ហាញស្នាដៃសិស្ស។

សិស្សទាំងអស់ស្រឡាញ់ចូលចិត្តអ្នកគ្រូ អៀង ជាខ្លាំង ពីព្រោះគាត់ចិត្តល្អមានភាពអាណិតអាសូ និងពិតជាមានចិត្តជួយដល់កាសិក្សារបស់ក្មេងៗ។ សិស្សទាំងអស់ពេលខ្លះហៅគាត់ថា “ម៉ាក់” គាត់មានទំនាក់ទំនងយ៉ាងល្អ ជាមួយសិស្សរបស់គាត់។

គាត់និយាយថា “ការបង្រៀនក្មេងៗ ពេលខ្លះដូចជាការលេងជាមួយពួកគេ” ។ គាត់បន្តថា “ការបង្រៀនសិស្សនៅថ្នាក់ទីមួយតម្រូវឱ្យមានការរៀបចំជាច្រើន ប៉ុន្តែខ្ញុំនៅតែធ្វើវាដោយខ្លួនឯងព្រោះខ្ញុំចូលចិត្តធ្វើវា”។ នៅពេលដែលយើងសាកសួរឪពុកម្តាយរបស់សិស្សពួកគាត់និយាយថា កូនៗរបស់ពួកគាត់មិនដែលអវត្តមាននោះទេ ព្រោះពួកគេចូលចិត្តរៀនជាមួយអ្នកគ្រូ អៀង ។

ដោយសារតែអ្នកគ្រូអៀងជាគ្រូល្អមួយរូប គាត់ក៏បានជួយសម្របសម្រួលសកម្មភាពមិត្តបង្រៀនមិត្តដែលជាផ្នែកមួយនៃកម្មវិធីបណ្តាញកុមារជួយកុមារ ។ ដែលត្រូវជ្រើសរើសសិស្សថ្នាក់ទី៥ និងទី៦ដើម្បីជួយបង្រៀនសិស្សថ្នាក់ទី១ និងទី២ ។ ជាងនេះទៅទៀតគាត់ក៏ត្រូវបានតែងតាំងជាប្រធានក្រុមបច្ចេកទេសនៅក្នុងសាលាកម្រងផងដែរ ។ យោងទៅតាមជំនាញ និងភាពលេចធ្លោរបស់អ្នកគ្រូក្នុងសាលារៀន ថ្មីៗនេះអ្នកគ្រូក៏ទទួលបានលិខិតសរសើរពីការិយាល័យអប់រំស្រុក ។ លោកនាយករបស់អ្នកគ្រូមានភាពសប្បាយរីករាយជាខ្លាំងទៅនឹងការងារដែលអ្នកគ្រូធ្វើ និងបានជួយគាំទ្រយ៉ាងខ្លាំងដល់ការចំរើនជឿនលឿនរបស់អ្នកគ្រូ ។



***ការលះបង់ក្នុងនាមជាគ្រូដ៏ល្អ* ៖ បន្ទាប់ពីទទួលការកសាងសមត្ថភាពពី IBEC អ្នកគ្រូអៀង អាចបង្កើតនូវបរិស្ថានសិក្សាវិជ្ជមានសម្រាប់សិស្សរបស់គាត់**

## សមាសភាគ៣ ៖ ការកែលម្អការគ្រប់គ្រងសាលារៀន និងការចូលរួមពីសហគមន៍

ដោយការអនុវត្តគម្រោងសម្រាប់ឆ្នាំទី៥បានចាប់ផ្តើម ក្រុមការងារផ្នែកកសាងសមត្ថភាពបានចាប់ផ្តើមធ្វើការវាយតម្លៃចោះៗពីផលប៉ះពាល់លើការបំប៉នស្តីពីភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងសាលារៀន ។ បំណងក្នុងការវាយតម្លៃនេះដើម្បីវាស់នូវប្រសិទ្ធភាពរបស់វគ្គ ដែលទាក់ទងទៅនឹងការងាររបស់បុគ្គលិករដ្ឋបាលសាលារៀន ។ ក្នុងខេត្តកំពង់ចាម មានសាលាមធ្យមសិក្សាចំនួន ១៥ និងបឋមសិក្សាចំនួន៥ ត្រូវបានធ្វើការវាយតម្លៃ ។

ដោយក្នុងខេត្តសៀមរាបមានបឋមសិក្សាចំនួន ១៨ និងមធ្យមសិក្សាចំនួន ១៨ត្រូវបានវាយតម្លៃ និង ប្រហែល១៥ មធ្យមសិក្សា និង ១០ បឋមសិក្សាសម្រាប់ខេត្តក្រចេះក៏ត្រូវបានវាយតម្លៃផងដែរ ។ សរុបមាន ៨២សាលារៀនត្រូវបានធ្វើការវាយតម្លៃ ។ ការវាយតម្លៃនេះផ្តោតលើចំណុចមួយចំនួនដូចជា វិធីសាស្រ្តគ្រប់គ្រងរបស់នាយកក្នុងសាលារៀន និងការគ្រប់គ្រងបរិស្ថានក្រៅសាលារៀន ការគ្រប់គ្រងទិន្នន័យ និងការគ្រប់គ្រងរដ្ឋបាល និងការងារបច្ចេកទេស ។ ការវាយតម្លៃលើការងារបច្ចេកទេសនេះគឺមានសារៈសំខាន់យ៉ាងខ្លាំង ដែលនាយកសាលាត្រូវលើកយកមកពិភាក្សាក្នុងពេលប្រជុំក្រុមបច្ចេកទេស ធ្វើការអង្កេតថ្នាក់រៀន ការផ្តល់នូវព័ត៌មានត្រឡប់វិជ្ជមានដល់លោកគ្រូ និងអ្នកគ្រូ និងការចូលរួមប្រជុំជាមួយសហគមន៍ ។ ក្នុងត្រីមាសនេះផងដែរ ក្រុមការងារបានធ្វើការស្រាវជ្រាវទៅលើនាយកសាលា និងគ្រូដើម្បីស្វែងរកថាតើពួកគាត់ចូលនិវត្តន៍ប៉ុន្មាននាក់ ប្តូរទៅសាលារៀនដ៏ទៃ ប្តូរតួនាទី ឬក៏បានស្លាប់ និងបាត់បង់កម្លាំងពលកម្ម ។ លទ្ធផលបានបង្ហាញនូវភាពស្មុគស្មាញខ្លាំងដោយអត្រាបាត់បង់ចំនួន ១៦.៣% ត្រូវបានរាយការណ៍ដោយសាលារៀនដែលបានគាំទ្រ ។

**ប្រសិនបើគម្រោងមួយឆ្ពោះទៅរកអត្រាបាត់បង់ ១៦%ក្នុងឆ្នាំនីមួយៗ វាមានន័យថាប្រហែលពាក់កណ្តាលនៃអ្នកបច្ចេកទេសសម្រាប់លើកកម្ពស់ការគ្រប់គ្រងដែលគម្រោងបានធ្វើសម្រាប់សាលារៀននេះនឹងអាចបាត់បង់ក្នុងអំឡុងពេល៣ឆ្នាំ និងស្ទើរតែបាត់បង់ទាំងអស់ក្នុងអំឡុងពេល៦ឆ្នាំ ។**

ការរកឃើញនេះធ្វើឱ្យមានភាពលំបាកដល់ផែនការកសាងសមត្ថភាពដែលគម្រោង IBEC បានជួបប្រទះ ។

# សមាសភាគ៤ ៖ ការកែលម្អបរិបទទំនាក់ទំនងអប់រំ

## *ការជំរុញការអភិវឌ្ឍតាមរយៈបំណិនជីវិត*

គម្រោងបានបន្តផ្តោតសំខាន់ ក្នុងការធ្វើការងារជាមួយក្រសួងអប់រំ ដើម្បីសម្រេចបន្ថែមក្នុងការជំរុញការសិក្សាបំណិនជីវិត ។ សរុបមានមធ្យមសិក្សាចំនួន ៩៦ក្នុងខេត្តគោលដៅ៣ គឺខេត្តកំពង់ចាម ក្រចេះ និងខេត្តសៀមរាប  ដែលអនុវត្តកម្មវិធីបំណិនជីវិតដំបូងគេក្នុងត្រីមាសកន្លងមក បន្ថែមលើសាលារៀនចំនួន៣០ ផ្សេងទៀតក្នុងខេត្តស្វាយរៀង ព្រៃវែង និងកំពង់ធំ ។

ដូច្នេះសាលារៀនសរុបចំនួន ១២៦ បានកំពុងអនុវត្តសកម្មភាពបំណិនជីវិតដោយប្រើកម្មវិធីសិក្សាថ្មី និងមានសម្ភារៈបង្រៀនភ្ជាប់ជាមួយ ។ ចំនួននេះរួមមានប្រហែល ៨%នៃចំនួនសាលាអនុវិទ្យាល័យ១,៦២២ ទូទាំងប្រទេស ។ តាមរបាយការណ៍របស់សាលារៀនចំនួន ៥៨៨ បានកំពុងស្នើសុំបង្រៀនកម្មវិធីបំណិនជីវិត ខណៈពេលដែលមធ្យមសិក្សាចំនួន ១១៦ បានរាយការណ៍ថា សាលារបស់គាត់កំពុងអនុវត្តកម្មវិធីបំណិនជីវិត។ យោងតាមចំនួននៃប្រធានបទដែលបានជ្រើសរើសដោយសាលារៀន យើងកត់សម្គាល់ឃើញថាមានប្រធានបទយ៉ាងតិចចំនួន៤ត្រូវបានសាលារៀននីមួយៗជ្រើសរើស (ឧទាហរណ៍៖ខេត្តក្រចេះ ) និងមានខេត្តមួយចំនួនទៀតមានចំនួនរហូតដល់៦ប្រធានបទ (ឧទាហរណ៍៖ខេត្តស្វាយរៀង) ។

អំឡុងពេលត្រីមាសនេះ មានគ្រូមធ្យមសិក្សាចំនួន១១៦នាក់ត្រូវបាន



***ការដាំផ្សិត ៖*** *សិស្សកំពុងសិក្សាអំពីការធ្វើកសិកម្មផ្សិត ដែលជាផ្នែកមួយនៃកម្មវិធីសិក្សាបំណិនជីវិត នៅសាលារៀនគោលដៅ*

អញ្ជើញចូលរួមវគ្គបំប៉នរំលឹកឡើងវិញរយៈពេលមួយថ្ងៃដើម្បីពង្រឹងនូវវិធីសាស្ត្របង្រៀនរបស់ពួកគាត់ និងពិភាក្សានូវបញ្ហាមួយចំនួនដែលកើតមានឡើងក្នុងពេល

## *វិធីសាស្ត្រថ្មីនៃការអប់រំស្តីពីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ៖*



អំឡុងពេលត្រីមាសនេះ ក្រុមការងារផ្នែក IT សម្រេចផ្តល់បន្ទប់កុំព្យូទ័របន្ថែមថ្មីមួយទៀត ដោយប្រើថវិកាសល់ពីឆ្នាំទី៤ ។ បន្ទប់កុំព្យូទ័រចុងក្រោយនេះត្រូវបានផ្តល់ឱ្យវិទ្យាល័យកំពង់ក្តី ក្នុងខេត្តសៀមរាប ។ ការបញ្ចប់នូវការសាងសង់បន្ទប់កុំព្យូទ័រចុងក្រោយនេះធ្វើឱ្យបន្ទប់កុំព្យូទ័រដែល IBEC បានផ្តល់ឱ្យសរុបកើនដល់ចំនួន ២៦ ។

***ជំនាញរបស់សិស្សសម្រាប់ថ្ងៃអនាគត ៖*** *សិស្សកំពុងអនុវត្តកម្មវិធី Open Office Writer ក្នុងបន្ទប់កុំព្យូទ័រដែលឧបត្ថម្ភដោយ IBEC ក្នុងខេត្តសៀមរាប (ឆ្វេង) ។*

**ដៃគូគម្រោង** IBEC គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជាបានទទួលថវិកាពីពលរដ្ឋអាមេរិកតាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ។ គម្រោងត្រូវបានប្រតិបត្តិដោយអង្គការអប់រំពិភពលោកដោយមានកិច្ចសហការជាមួយអង្គការខេប និងសហប្រតិបត្តិការជាមួយក្រសួងអប់រំ យុវជន និងកីឡា (MoEYS) ។ ដៃគូក្នុងស្រុកផ្សេងទៀត មានអង្គការ ៖ WCRD, BSDA, NEP, EDA និង Media One

*ព្រឹត្តិបត្រព័ត៌មាននេះអាចផលិតទៅបានដោយមានការឧបត្ថម្ភ ក្រោមជំនួយសប្បុរសធម៌ពីពលរដ្ឋអាមេរិកតាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ។*
*រាល់ខ្លឹមសារនៅក្នុងព្រឹត្តិបត្រនេះ ជាការទទួលខុសត្រូវរបស់អង្គការអប់រំពិភពលោក និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ USAID ឬរដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ ។*
*ការិយាល័យអង្គការអប់រំពិភពលោក ៖ ផ្ទះលេខ ២០ ផ្លូវ ២២២ ភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ ៨៥៥-២៣-២១៦ ៨៥៤* E-mail: worldedcam@worlded.org.kh